ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារលិខិតថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីគ្រងព្រះបរមសិរីរាជសម្បត្តិ**

**ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!**

ក្នុងឱកាសដ៏ឧត្តុង្គឧត្តម ក្នុងព្រះរាជពិធីបុណ្យខួបទី១៦ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២០នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមទូលព្រះបង្គំនិងភរិយា សូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្ត ក្រាបបង្គំទូលថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរ ថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំដល់កូនចៅប្រជារាស្ត្រប្រកបដោយភាពសុខដុមរមនា ចម្រុងចម្រើនរុងរឿងទាំងក្នុងពេលបច្ចុប្បន្ននិងទៅអនាគត។

នាឱកាសមហាជ័យមង្គលដ៏ថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមសម្តែងថ្វាយនូវកតញ្ញូកតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុត ចំពោះព្រះមហាករុណាទិគុណរបស់ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ជានិច្ចកាលព្រះអង្គតែងបានបំពេញព្រះរាជកិច្ចដ៏ឧត្តុង្គឧត្តម និងបានបូជាព្រះរាជកាយពលក្នុងបុព្វហេតុបម្រើជាតិមាតុភូមិ។ ព្រមជាមួយនេះព្រះអង្គបានប្រោសព្រះរាជទាននូវព្រះរាជទ្រព្យយ៉ាងច្រើនជួយដល់ប្រជារាស្ត្រទូទៅ និងតែងយកព្រះរាជហឫទ័យទុកដាក់ជាទីបំផុតរាល់ព្រះរាជកិច្ចសង្គម នាំមកនូវសុខសន្តិភាពនិងការអភិវឌ្ឍប្រកបដោយភាពសុខដុមរមនាសប្បុរសប្បាយ ថ្កុំថ្កើងរុងរឿងជូនប្រជារាស្ត្រទូទាំងប្រទេស។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្ត បួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ មានទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះរាជតេជបារមី នៃអតីតព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ ប្រោសព្រះរាជទានប្រសិទ្ធិពរជ័យ មហាប្រសើរ ថ្វាយ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ប្រកបដោយព្រះបរមសុខ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ដើម្បីបានគង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់ត្រជុំដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ព្រមទាំងប្រជារាស្ត្រខ្មែរអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈទ្រង់ព្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃ ចន្ទ ១០ កើត ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ០២៣ ៨៨៣ ២៧៥: generalsec@mod.gov.kh